**សូមក្រាបបង្គំទូលថ្វាយ**
**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា**

**បពិត្រ ព្រះករុណា** **ជាអម្ចាស់ជីវិតលើត្បូងជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត**

ជាបឋម ទូលព្រះបង្គំជាខ្ញុំនិងភរិយា សូមថ្លែងអំណរព្រះរាជគុណប្រកបដោយបីតិសោមនស្សរីករាយជាអនេកប្បការ ដោយបានទទួលព្រះរាជសារលិខិតព្រះករុណាថ្លៃវិសេស ដែលទ្រង់សព្វព្រះរាជហឫទ័យ ប្រោសព្រះរាជទាននូវការអបអរសាទរ ព្រមទាំងប្រសិទ្ធពរបវរមហាប្រសើរ ចំពោះទូលព្រះបង្គំជាខ្ញុំនិងភរិយា រួមទាំងក្រុមគ្រួសារ ក្នុងឱកាសដ៏ថ្លៃថ្លាដែលទូលព្រះបង្គំជាខ្ញុំមានមហាកិត្តិយសទទួលគោរមងារ "**សាស្ត្រាចារ្យកិត្តិយសផ្នែកទំនាក់ទំនងអន្តរជាតិ**" ពីសាកលវិទ្យាល័យប៉េកាំង នាថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ២០១៩ នៅសាធារណរដ្ឋប្រជាមានិតចិន ។

ក្នុងវោកាសដ៏ឧត្តុង្គឧត្តមជាប្រវត្តិសាស្ត្រនេះ ទូលព្រះបង្គំជាខ្ញុំនិងភរិយា សូមព្រះបរមរាជានុញ្ញាតដ៏ខ្ពង់ខ្ពស់បំផុត សម្តែងថ្វាយយ៉ាងឧឡារិកចំពោះជោគជ័យជាវិជ្ជមាន ដែលទូលព្រះបង្គំបានទទួលនាឱកាសនេះ គឺជាកិត្យានុភាព នៃព្រះរាជាណាចក្រកម្ពុជាទាំងមូល ហើយក៏ជាជោគជ័យនៃប្រជាពលរដ្ឋខ្មែរគ្រប់រូបនៅក្រោមម្លប់ **ជាតិ សាសនា ព្រះមហាក្សត្រ** ពិសេសតេជៈសម្ភារឫទ្ធាបារមី នៃ**ព្រះករុណា អង្គព្រះមហាក្សត្រ** ព្រមទាំង **សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ** ជាអម្ចាស់ជីវិតតម្កល់ត្បូង ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត ដែលព្រះអង្គទាំងទ្វេតែងប្រទាននូវការគាំទ្រជាអតិបរមាចំពោះកិច្ចខិតខំប្រឹងប្រែង បំរើជាតិ របស់ទូលព្រះបង្គំរៀងរហូតមក ។

ជាថ្មីម្តងទៀត ទូលព្រះបង្គំជាខ្ញុំនិងភរិយា សូមលំឱនកាយក្រាបថ្វាយព្រះសព្ទសាធុការពរមហាប្រសើរ សូមព្រះករុណា ជាអម្ចាស់ជីវិតលើត្បូង ស្តេចទ្រង់ព្រះប្រកបដោយព្រះពុទ្ធពរទាំងបួនប្រការគឺ: **អាយុ វណ្ណៈ សុខៈ ពលៈ** កុំបីឃ្លៀងឃ្លាតឡើយ ។

សូម **ព្រះករុណា** ថ្លៃវិសេស ស្តេចទ្រង់ប្រោសព្រះរាជមេត្តាទទួលនូវអភិវន្ទនកិច្ច និងកតញ្ញុតាធម៌ដ៏ខ្ពង់ខ្ពស់បំផុតពីទូលព្រះបង្គំជាខ្ញុំ និងភរិយា ។

ធ្វើនៅថ្ងៃ សុក្រ ០៧ រោច ខែ ចេត្រ ឆ្នាំ កុរ ឯកស័ក ព.ស ២៥៦២
ត្រូវនឹងថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០១៩

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**